**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**យូនីត (ខេមបូឌា) ខូអេលធីឌី**

**U-KNITS (CAMBODIA) CO., LTD**

អាស័យដ្ឋានៈ ផ្លូវជាតិលេខ២ ភូមិព្រៃកហ្វូរលិច សង្កាត់ព្រៃកហ្វូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល

# កិច្ចព្រមព្រៀង

**ស្តីពីការប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល២៩ថ្ងៃ គឺចាប់ពីថ្ងៃទី២២ ខែកក្កដា ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣**

*អង្គប្រជុំបានឯកភាព និងព្រមព្រៀងដូចខាងក្រោម៖*

នៅថ្ងៃសុក្រ៥រោច ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោងដប់បីរសៀល មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន យូនីត (ខេមបូឌា) ដែលមានអាស័យដ្ឋានស្ថិតនៅផ្លូវជាតិលេខ២ ភូមិព្រៃកហ្វូរលិច សង្កាត់ព្រៃកហ្វូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានកម្មករសរុប ៩៣៧នាក់ (៧៣១ស្រី) ដែលមានលោកស្រី JI SEUNG HEE ជាអ្នកគ្រប់គ្រងទូទៅ តំណាងអោយលោក SOHN CHHON IK ជនជាតិកូរ៉េ ជានាយកក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករចំនួន៣១ថ្ងៃ ។

ជាកិច្ចចាប់ផ្តើមលោកស្រី JI SEUNG HEE ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោកប្រធាន អង្គប្រជុំបានមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់ពីមូលហេតុដោយសារតែក្រុមហ៊ុន កង្វះការបញ្ជាទិញ ដូច្នេះក្រុមហ៊ុន យូនីត (ខេមបូឌា) និងតំណាងប្រតិភូបុគ្គលិក និងសហជីពនៃកម្មករនិយោជិតទាំងអស់បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១. ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៩២៩នាក់ រយៈពេល២៩ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២២ ខែកក្កដា រហូតដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។

២. ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ដល់កម្មករនិយោជិតដូចខាងក្រោមៈ

- ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភចំនួន **១៥** ដុល្លារអាមេរិច សម្រាប់រយៈពេលព្យួរកិច្ចសន្យាការងាររយៈពេល **១០**ថ្ងៃ គឺចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣។
- ក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ៣០ ដុល្លារអាមេរិច សម្រាប់រយៈពេលព្យួរកិច្ចសន្យាការងាររយៈពេល ១៩ថ្ងៃ គឺចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣ ។

ថ្ងៃសុក្រ៥រោច ខែបឋមសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

តាខ្មៅ, ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យូនីត (ខេមបូឌា) ខូអិលធីឌី U-KNITS (CAMBODIA) Co., LTD.

SOHN CHOON IK

បានឃើញ និងឯកភាព

តំណាងសហជីព

- ហ៊ុន ចាន់រី

បានឃើញ និងឯកភាព

ប្រតិភូបុគ្គលិក (តំណាងកម្មករ)

- ម៉ន យុទ្ធា
- ខន សាឯម
- ជា ចាន់ណាប
- នាង ចាន្ធូ

- ហ៊ុន ចាន់រី
- ម៉ាយ សេដា
- ពៅ សុខរ៉េត
- ប៉ែន សារិទ្ធ

- ជាប សុខណា
- ជឿន សម្បូរ
- លន់ សុខរ៉ន